**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*********

**កិច្ចព្រមព្រៀង**

**រវាង**

**រោងចក្រ អេវ៉ាយស៊ី ហ្គាមិន ហ្វេកធើរី ឯ.ក ជាមួយ**

**តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំរោងចក្រ**

**ស្តីពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ១៣:០០នាទីរសៀល នៅក្នុងរោងចក្រ អេវ៉ាយស៊ី ហ្គាមិន ហ្វេកធើរី ឯ.ក មានកិច្ចប្រជុំមួយរវាងតំណាងរោងចក្រ នឹងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះ នាយករោងចក្របានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ន រោងចក្រខ្វះការបញ្ជាទិញ ដែលបណ្តាលឱ្យច្រវាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះរោងចក្រសម្រេចចិត្ត ព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ៧០៥នាក់ (ស្រី ៤៥៨នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ៧០៥នាក់ (ស្រី ៤៥៨នាក់) រយៈពេល ៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣។ ក្នុងអំឡុងពេលព្យួរការងារនេះ កម្មករនិយោជិកបានឯកភាពទទួលការផ្តល់ជូនរបស់រោងចក្រនូវប្រាក់ឧបត្ថម្ភ ចំនួន ៦០ដុល្លា។ ក្នុងករណីមានការកែប្រែនូវលក្ខខណ្ឌណាមួយក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ដែរជាគោលការណ៍កំណត់ថ្មីរបស់អាជ្ញាធរមានសមត្ថកិច្ច (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) នោះការព្រមព្រៀងនឹងអនុវត្តតាមគោលការណ៍ថ្មីនោះ។

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងានេះ និងបើកជូនបងប្អូនកម្មករនិយោជិតដូចខាងតទៅ៖

- លើកទី១ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ ចំនួន ៣០ដុល្លា
- លើកទី២ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ចំនួន ៣០ដុល្លា។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១៤:៣០នាទី រសៀលនាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និត ស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោបល់សហការគ្នាយ៉ាងរលូន។

ថ្ងៃអង្គារ ១២រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកណ្តាល ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣

ជ.នាយករោងចក្រ

AYC GARMENT FACTORY CO., LTD. KINGDOM OF CAMBODIA

**ស្នាមមេដៃតំណាងកម្មករ និយោជិក និងតំណាងសហជីព**